# ច្បាប់

ស្តីពី

# គណបក្សនយោបាយ

ជស/រកម/១១៩៧/០៧

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល
លេខ.១៩៥៣........
ថ្ងៃទី១៨.១១.៩៧.ម៉ោង. ...
បញ្ជូនទៅ.....................

*********

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៥៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់បែបបទនិងល័ក្ខខ័ណ្ឌនៃការបង្កើត ការចុះបញ្ជីនិងការធ្វើសកម្មភាពរបស់គណបក្សនយោបាយក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

គណបក្សនយោបាយ គឺជាក្រុមមនុស្សដែលមានគំនិតនិងឆន្ទៈស្របគ្នា ហើយរួបរួមគ្នាដោយស្ម័គ្រចិត្តតាមកិច្ចសន្យា បង្កើតឡើងនូវអង្គការមួយដែលមានលក្ខណៈអចិន្ត្រៃយ៍ និងស្វ័យភាព ដើម្បីចូលរួមក្នុងឆាកនយោបាយជាតិតាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញនិងច្បាប់ពាក់ព័ន្ធជាធរមាន ។

**មាត្រា ៣.-**

គ្រប់គណបក្សនយោបាយត្រូវមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញឬទីរួមខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

គ្រប់គណបក្សនយោបាយមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបុព្វសិទ្ធិនិងការយកចិត្តទុកដាក់ដោយស្មើភាពគ្នា ពីរាជរដ្ឋាភិបាលនិងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ។

**មាត្រា ៥.-**

ការចូលជាសមាជិករបស់គណបក្សនយោបាយណាមួយ គឺជាការជ្រើសរើសផ្ទាល់ខ្លួនដោយសេរីរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។ គ្មានជនណាម្នាក់មានសិទ្ធិបង្ខិតបង្ខំឲ្យគេចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ។

គ្មានជនណាម្នាក់ត្រូវបានគេដកហូតសិទ្ធិក្នុងការអនុវត្តសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ឬសិទ្ធិវិជ្ជាជីវៈ ដោយសារមូលហេតុជននោះជាសមាជិកឬមិនមែនជាសមាជិករបស់គណបក្សនយោបាយណាមួយ ដែលបង្កើតឡើងដោយស្របច្បាប់នោះទេ ។

**មាត្រា ៦.-**

គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយ ដូចខាងក្រោមនេះ :

១-ធ្វើឱ្យមានអបគមន៍ ដែលនាំឱ្យអន្តរាយដល់ឯកភាពជាតិនិងបូរណភាពដែនដី ។

២-ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្សដោយប្រើប្រាស់មធ្យោបាយហិង្សាក្នុងគោលបំណងដណ្ដើមអំណាច ។

៣-បង្កើតកងកម្លាំងប្រដាប់អាវុធ ។

**មាត្រា ៧.-**

គ្រប់គណបក្សនយោបាយមិនត្រូវស្ថិតនៅក្រោមចំណុះឬការបញ្ជាបញ្ជារបស់គណបក្សនយោបាយបរទេសឬរបស់រដ្ឋាភិបាលបរទេស ។

**មាត្រា ៨.-**

ការចុះបញ្ជីគណបក្សនយោបាយជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ២

## ការបង្កើតគណបក្សនយោបាយ

**មាត្រា ៩.-**

ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០នាក់ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិផ្ដើមបង្កើតគណបក្សនយោបាយមួយបាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខអក្សរទៅក្រសួងមហាផ្ទៃ ។ ក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាលាយលក្ខអក្សរថាបានទទួលសេចក្ដីជូនដំណឹងនេះ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ ។ បើហួសការកំណត់ ១៥ថ្ងៃនេះ ត្រូវចាត់ទុកថាបានទទួលសេចក្ដីជូនដំណឹងនេះ ។

គណបក្សនយោបាយដែលទើបផ្ដើមបង្កើតត្រូវធ្វើការបោះឆ្នោតជ្រើសតាំងគណៈ-កម្មាធិការបណ្ដោះអាសន្នដែលមានសមាជិកយ៉ាងតិច ៧រូប ហើយដែលម្នាក់ៗមានអាយុយ៉ាងតិច ២៥ឆ្នាំ សម្រាប់រៀបចំបែបបទនិងបំពេញលក្ខខណ្ឌនៃការសុំចុះបញ្ជីគណបក្សនយោបាយតាមការកំណត់ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ដើម្បីទទួលសុពលភាព ។

ទោះបីមិនទាន់ទទួលសុពលភាពក៏ដោយ ក្នុងរយៈពេលនេះ គណបក្សនយោបាយអាចបើកផ្លាកនៅទីស្នាក់ការរបស់ខ្លួនបាន ។

មាត្រា ១០.-

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំលក្ខន្តិកៈនិងគោលនយោបាយសំខាន់ៗ ជាលាយលក្ខអក្សរ ដែលមានចំណុចសំខាន់ៗយ៉ាងតិចណាស់ដូចខាងក្រោមនេះ :

ក-លក្ខន្តិកៈត្រូវមាន :

១-ឈ្មោះជាអក្សរពេញ អក្សរកាត់និងសញ្ញាសំគាល់ ។

២-អាស័យដ្ឋាននៃទីស្នាក់ការកណ្តាល ។

៣-កាលបរិច្ឆេទនៃការបង្កើតគណបក្សនយោបាយ ។ កាលបរិច្ឆេទគណបក្សនយោបាយនេះ មិនត្រូវជាន់លើថ្ងៃបុណ្យជាតិនិងអន្តរជាតិ ។

៤-វិធានស្តីពីការបញ្ចូលជាសមាជិកភាពនិងការបណ្តេញចេញពីសមាជិកភាព ។

៥-សិទ្ធិនិងភារកិច្ចរបស់សមាជិក ។

៦-រចនាសម្ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមបន្តបន្ទាប់ ។

៧-សមត្ថកិច្ចនៃអង្គការនានារបស់គណបក្សនយោបាយ ។

៨-របៀបបទនៃការជ្រើសរើសនិងដកហូតមុខងាររបស់សមាជិកគណៈកម្មាធិការនាយក ។

៩-ការកំណត់អំពីការប្រជុំសាមញ្ញ នៃអង្គការនានារបស់គណបក្សនយោបាយ។

១០-ចំនួនសមាជិកចាំបាច់ "កូរ៉ុម" ដែលត្រូវចូលរួមក្នុងអង្គប្រជុំនៃអង្គការនានារបស់គណបក្សនយោបាយ ដើម្បីឱ្យអង្គប្រជុំនោះយកជាការបាន ។

១១-ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ ។

១២-វិធានស្តីពីការរំលាយគណបក្សនយោបាយនិងការបាត់បែងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ នៅពេលត្រូវរំលាយ ។

១៣-វិធានស្តីពីការធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្សនយោបាយ ។

ខ-គោលនយោបាយនិងកម្មវិធីនយោបាយសំខាន់ៗ ត្រូវចែងអំពីគោលបំណងនិងវត្ថុបំណងរបស់គណបក្សនយោបាយ ។

មាត្រា ១១.-

គ្រប់គណបក្សនយោបាយត្រូវមានឈ្មោះនិងសញ្ញាសំគាល់តាមការកំណត់ដូចខាងក្រោម :

១-ឈ្មោះជាអក្សរពេញ ជាអក្សរកាត់និងសញ្ញាសំគាល់របស់គណបក្សនយោបាយ ត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញឬអក្សរកាត់និងសញ្ញាសំគាល់របស់គណបក្សនយោបាយនានា ។

២-ឈ្មោះរបស់គណបក្សនយោបាយដែលទើបបង្កើតថ្មីមិនត្រូវធ្វើឡើងដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចទៅលើឈ្មោះគណបក្សនយោបាយនានា ។

៣-សញ្ញាសំគាល់របស់គណបក្សនយោបាយមិនត្រូវចម្លងឬយកតាមសញ្ញាជាតិ រូបភាពតំណាងឱ្យសាសនា ប្រាសាទអង្គរវត្តឬព្រះឆាយាល័ក្ខណ៍ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ។

## ជំពូកទី ៣

## សមាជិកភាព

មាត្រា ១២.-

ប្រជាពលរដ្ឋខ្មែរដែលមានអាយុយ៉ាងតិច១៨ឆ្នាំនិងមានសិទ្ធិពលរដ្ឋអាចចូលជាសមាជិកគណបក្សនយោបាយបាន ។

មាត្រា ១៣.-

ការចូលជាសមាជិកនៃគណបក្សនយោបាយ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។

សមាជិកគណបក្សនយោបាយអាចលាឈប់ពីគណបក្សនយោបាយបានគ្រប់ពេលវេលា ដោយមិនចាំបាច់បញ្ជាក់ពីមូលហេតុឡើយ ។

មាត្រា ១៤.-

សមាជិកគណបក្សនយោបាយមានសិទ្ធិ ការពារកិច្ចដូចគ្នាស្របតាមលក្ខន្តិកៈនៃគណបក្សនយោបាយ ។

**មាត្រា ១៥.-**

ប្រជាពលរដ្ឋខ្មែរម្នាក់មិនអាចជាសមាជិកគណបក្សនយោបាយលើសពីមួយក្នុងពេលតែមួយបានទេ ។ ក្នុងករណីដែលបុគ្គលមួយរូបចូលជាសមាជិកគណបក្សនានាយ៉ាងច្រើន សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយត្រូវចាត់ទុកជាបានការ ។

បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទនិងកងកម្លាំងនគរបាលជាតិ អាចចូលជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទនិងកងកម្លាំងនគរបាលជាតិទេ ។

**មាត្រា ១៦.-**

សមាជិកគណបក្សនយោបាយត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ :

១-បានលាឈប់ឬបានបោះបង់សមាជិកភាពនៃគណបក្សនយោបាយ ។

២-ត្រូវបានបណ្តេញចេញពីគណបក្សនយោបាយស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយសាមី។

## ជំពូកទី ៤

## អង្គការនាយករបស់គណបក្សនយោបាយ

**មាត្រា ១៧.-**

អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ ត្រូវមានយ៉ាងតិចដូចខាងក្រោម :

-មហាសន្និបាតឬសមាជឬអង្គការសមមូល ។

-ក្រុមប្រឹក្សាជាតិឬគណៈកម្មាធិការកណ្តាលឬអង្គការសមមូល ។

-គណៈកម្មាធិការនាយកឬគណៈកម្មាធិការអចិន្ត្រៃយ៍ឬអង្គការសមមូល ។

-គណៈកម្មាធិការអាជ្ញាកណ្តាលឬគណៈកម្មាធិការត្រួតពិនិត្យឬគណៈកម្មាធិការវិវាទឬអង្គការសមមូល ។

ឈ្មោះអង្គការដឹកនាំរបស់គណបក្សនយោបាយគ្រប់ថ្នាក់នេះ អាចប្រែប្រួលអាស្រ័យទៅតាមការកំណត់របស់លក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ ។

មាត្រា ១៨.-

អាណត្តិ ភារកិច្ច ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ តាមការកំណត់ដូចមានចែងក្នុងមាត្រា១៧ នៃច្បាប់នេះនិងអង្គការនានាទៀតរបស់គណបក្សនយោបាយ ត្រូវកំណត់ក្នុងលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៥

## ការចុះបញ្ជីគណបក្សនយោបាយ

មាត្រា ១៩.-

ដើម្បីទទួលសុពលភាពដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៩ នៃច្បាប់នេះ គណបក្សនយោបាយត្រូវសុំចុះបញ្ជីគណបក្សនយោបាយ ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០នាក់ មកពីបណ្តាខេត្ត ក្រុងមួយចំនួន ។

មាត្រា ២០.-

គណបក្សនយោបាយ ត្រូវបំពេញបែបបទនិងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ពាក្យសុំចុះបញ្ជីគណបក្សនយោបាយ ត្រូវមានហត្ថលេខារបស់ប្រធានគណបក្សនយោបាយ ។

២-ឈ្មោះជាអក្សរពេញនិងអក្សរកាត់និងសញ្ញាសំគាល់របស់គណបក្សនយោបាយ ។

៣-អាស័យដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ។

៤-ច្បាប់ដើមនៃលក្ខន្តិកៈគណបក្សនយោបាយចំនួនពីរច្បាប់ ។

៥-បទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយប្រសិនបើមាន ។

៦-គោលនយោបាយនិងកម្មវិធីនយោបាយសំខាន់ៗរបស់គណបក្សនយោបាយ ។

៧-សេចក្តីថ្លែងការណ៍ជាលាយលក្ខអក្សររបស់គណបក្សនយោបាយស្តីពីការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយនិងបទប្បញ្ញត្តិផ្សេងៗជាធរមាននិងគោលការណ៍នៃលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនិងការគោរពសិទ្ធិមនុស្ស ។

៨-បញ្ជីឈ្មោះដោយមានអាយុ អាស័យដ្ឋាននិងស្នាមមេដៃរបស់សមាជិកទាំង ៤០០០នាក់ ដោយមានបញ្ជាក់លេខ ប័ណ្ណសមាជិកគណបក្សនិងកាលបរិច្ឆេទនៃការចូលសមាជិកភាពគណបក្សនយោបាយ ។

៩-ជីវប្រវត្តិសង្ខេបរបស់ប្រធានឬស្ថាបនិកចំនួន ៣ នាក់យ៉ាងតិច ក្នុងមួយនាក់មួយច្បាប់ ដោយមានបិទរូបថតទំហំ ៤ គុណនឹង ៦ ។

១០-សេចក្ដីប្រកាសអំពីគណនីធនាគារ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

១១-បង្កាន់ដៃថ្លៃអាករចុះបញ្ជីគណបក្សនយោបាយមួយច្បាប់ ។ ថ្លៃអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២១.-**

ក្រសួងមហាផ្ទៃត្រូវចេញបង្កាន់ដៃទទួលពាក្យសុំមួយច្បាប់ ឱ្យគណបក្សនយោបាយដែលបានបំពេញនូវទម្រង់បែបបទគ្រប់គ្រាន់ តាមការកំណត់ដូចមានចែងក្នុងមាត្រា ២០នៃច្បាប់នេះ។

**មាត្រា ២២.-**

ក្រសួងមហាផ្ទៃត្រូវពិនិត្យខ្លឹមសារនៃសំណុំឯកសាររបស់គណបក្សនយោបាយបន្ទាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យសុំ ដូចមានចែងក្នុងមាត្រា ២១នៃច្បាប់នេះ ។

ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ក្រសួងមហាផ្ទៃត្រូវសម្រេចយល់ព្រមឬមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយ ។

**មាត្រា ២៣.-**

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយណាមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីគណបក្សនយោបាយនិងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតឆ្លើយតបស្ដីពីការយល់ព្រមឱ្យចុះបញ្ជី ផ្ញើជូនទៅសាមីគណបក្សនយោបាយនោះវិញ ដោយភ្ជាប់ជាមួយនូវលក្ខន្តិកៈមួយច្បាប់ ដែលមានចារបញ្ជាក់កាលបរិច្ឆេទនៃការចុះបញ្ជីគណបក្សនយោបាយ ដោយមានចុះហត្ថលេខានិងត្រារបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.-**

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយ ដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីគណបក្សនយោបាយនិងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតជូនដំណឹងផ្ញើជូនទៅសាមីគណបក្សនយោបាយនោះវិញ។ គណបក្សនយោបាយនោះត្រូវបំពេញបន្ថែមលើសំណុំឯកសារតាមលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃយ៉ាងយូរ ១៥ថ្ងៃ រាប់ពីថ្ងៃទទួលលិខិតនេះ ។ បើហួសរយៈពេលកំណត់ ១៥ថ្ងៃនេះ ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយផ្ញើជូនទៅសាមីគណបក្សនយោបាយ ។

មាត្រា ២៥.-

គណបក្សនយោបាយណា ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយនោះ ។

ក្រោយពីបានទទួលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលសម្រេចលើភាពត្រឹមត្រូវនៃខ្លឹមសារនៃសំណុំឯកសាររបស់គណបក្សនយោបាយនោះ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីគណបក្សនយោបាយនោះភ្លាម តាមការកំណត់ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

មាត្រា ២៦.-

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះឬកែប្រែគោលនយោបាយនិងកម្មវិធីនយោបាយសំខាន់ៗឬធ្វើវិសោធនកម្មលើលក្ខន្តិកៈបានស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយខ្លួន។ ក្នុងករណីនេះ គណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវសំណុំឯកសារថ្មីដែលកែប្រែរួចហើយ។ ដោយឡែកការផ្លាស់ប្តូរប្រធានគណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់ប្រធានថ្មីដោយមានរូបថតទំហំ ៤ គុណនឹង ៦ ។

# ជំពូកទី ៦

## ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

មាត្រា ២៧.-

ចាត់ទុកជាហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ចំណូលដែលបានមកពី :

១-វិភាគទានឬភាគទានរបស់សមាជិក ។

២-ចំណូលផ្សេងៗរបស់គណបក្សនយោបាយដែលបានមកពីការធ្វើអាជីវកម្មស្របច្បាប់ ។

៣-ប្រាក់ពីថវិការបស់រដ្ឋតាមការកំណត់ ដូចមានចែងក្នុងមាត្រា ២៨នៃច្បាប់នេះ ។

៤-អំណោយរបស់ក្រុមហ៊ុនឯកជនខ្មែរឬសប្បុរសជនខ្មែរ ។

៥-ទ្រព្យសម្បត្តិផ្ទាល់របស់គណបក្សនយោបាយ ។

**មាត្រា ២៨.-**

រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នាដល់គ្រប់គណបក្សនយោបាយសម្រាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណបក្សនយោបាយណាដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន៣% នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអាសនៈមួយក្នុងសភា គណបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេល៣ខែយ៉ាងយូរ ចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរ នៃការបោះឆ្នោត ។

**មាត្រា ២៩.-**

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគម អង្គការក្រៅរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈឬក្រុមហ៊ុនបរទេស លើកលែងតែករណីដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ ។

## ជំពូកទី ៧

## របាយការណ៍និងការត្រួតពិនិត្យ

**មាត្រា ៣០.-**

របាយការណ៍និងឯកសារពាក់ព័ន្ធនឹងគណនេយ្យ ត្រូវតម្កល់ទុករយៈពេលយ៉ាងតិច៧ឆ្នាំ ហើយអាចអនុញ្ញាតឱ្យត្រួតពិនិត្យ ដោយអនុលោមតាមលក្ខន្តិកៈឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយឬការសម្រេចរបស់តុលាការឬស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៣១.-**

គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយរួចហើយ ត្រូវផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។ របាយការណ៍ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយនិងហេរញ្ញិក ។

របាយការណ៍នេះត្រូវមានខ្លឹមសារនិងឯកសារដូចខាងក្រោម :

១-សកម្មភាពសំខាន់ៗរបស់គណបក្សនយោបាយ ។

២-តារាងតុល្យភាពដែលបង្ហាញនូវប្រាក់ចំណូលនិងប្រាក់ចំណាយប្រចាំឆ្នាំតាមប្រភេទ ។ តារាងតុល្យភាពនេះត្រូវរៀបចំឡើងដោយគណនេយ្យរបស់គណបក្សនយោបាយ ។

៣-បញ្ជីគណនេយ្យការគណនីរបស់គណបក្សនយោបាយនៅក្នុងធនាគារ ។

៤-បញ្ជីគណនេយ្យការនៃទ្រព្យសម្បត្តិទាំងអស់ រាប់បញ្ចូលទាំងទ្រព្យសម្បត្តិជាកម្មសិទ្ធិឬផលកម្រៃក្នុងជំនួញនិងបំណុលរបស់គណបក្សនយោបាយ ។

**មាត្រា ៣២.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវក្នុងការពិនិត្យបញ្ជីគណនេយ្យការទាំងឡាយដែលមានចែងក្នុងចំណុច ២,៣,៤ មាត្រា ៣១ នៃច្បាប់នេះ ។

## ជំពូកទី ៨

## ការរំលាយ ការរួបបញ្ចូលគ្នានិងការធ្វើសម្ព័ន្ធភាពគណបក្សនយោបាយ

**មាត្រា ៣៣.-**

គណបក្សនយោបាយអាចរំលាយខ្លួនឯងបាន តាមសេចក្ដីសម្រេចរបស់មហាសន្និបាតដោយអនុលោមតាមលក្ខន្តិកៈរបស់ខ្លួន បន្ទាប់ពីបានធ្វើការជំរះបញ្ជីនិងចាត់ចែងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ ។ គណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខអក្សរពីការរំលាយនេះដល់ក្រសួងមហាផ្ទៃភ្លាម ដើម្បីលុបឈ្មោះគណបក្សនយោបាយនោះ ចេញពីបញ្ជីគណបក្សនយោបាយ ។

**មាត្រា ៣៤.-**

គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយលើកលែងតែគណបក្សនយោបាយនោះ ត្រូវបានប្រកាសរំលាយតាមសាលក្រមឬសាលដីកាជាស្ថាពររបស់តុលាការ ។

**មាត្រា ៣៥.-**

គណបក្សនយោបាយដែលត្រូវបានប្រកាសរំលាយដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការចាត់ចែងទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់មហាសន្និបាត ។

**មាត្រា ៣៦.-**

គណបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបាន តាមការកំណត់របស់លក្ខន្តិកៈ ។ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែង ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់មហាសន្និបាតគណបក្សនយោបាយ ។

ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះគណបក្សនយោបាយដែលបានប្រកាសរួមបញ្ចូលគ្នានោះចេញពីបញ្ជីគណបក្សនយោបាយ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីការរួមបញ្ចូលនោះ។

**មាត្រា ៣៧.-**

គណបក្សនយោបាយអាចធ្វើសម្ព័ន្ធភាពទ្វេភាគីឬពហុភាគីជាមួយគ្នាបានដោយសេរីតាមសេចក្ដីសម្រេចរបស់គណបក្សនយោបាយនីមួយៗ ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៣៨.-**

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ចំនួនបីលានរៀល ( ៣.០០០.០០០រៀល ) ចំពោះ គណបក្សនយោបាយណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣១ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរហើយអាចផ្ដន្ទាទោសព្យួរសកម្មភាពគណបក្សនយោបាយនោះជាបណ្ដោះអាសន្ន ។

**មាត្រា ៣៩.-**

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី បីលានរៀល ( ៣.០០០.០០០រៀល ) ដល់ប្រាំលានរៀល ( ៥.០០០.០០០រៀល ) ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើស នឹងមាត្រា ៧ និងមាត្រា ២៩ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរហើយអាចព្យួរសកម្មភាពគណបក្សនយោបាយនោះជាបណ្ដោះអាសន្ន ។

**មាត្រា ៤០.-**

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ចំនួន មួយលានរៀល ( ១.០០០.០០០រៀល ) ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ និងវាក្យខណ្ឌទី ២ នៃមាត្រា ១៩ នៃច្បាប់នេះ ។

**មាត្រា ៤១.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីមួយលានរៀល ( ១.០០០.០០០រៀល ) ដល់ ប្រាំលានរៀល (៥.០០០.០០០រៀល) និងឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ចំពោះ ជនណាដែលបានប្រព្រឹត្តដូចខាងក្រោម :

១-បន្តគ្រប់គ្រង ដឹកនាំគណបក្សនយោបាយដែលក្រសួងមហាផ្ទៃមិនយល់ព្រមឱ្យចុះក្នុងបញ្ជីគណបក្សនយោបាយ ឬ

២-បន្តគ្រប់គ្រងដឹកនាំគណបក្សនយោបាយ ដែលតុលាការបានចេញសាលក្រមឬសាលដីកាជាស្ថាពររំលាយរួចហើយ ឬ

៣-គ្រប់គ្រង ដឹកនាំគណបក្សនយោបាយដោយមិនបានសុំចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយក្នុងរយៈពេលលើសពី ១៨ខែ គិតចាប់តាំងពីថ្ងៃធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្នដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ឬ

៤-នៅតែបន្តបើកទីស្នាក់ការគណបក្សនយោបាយខ្លួន ទោះជាមានសាលក្រម ឬសាលដីកាជាស្ថាពររបស់តុលាការសម្រេចរំលាយឬផ្អាកសកម្មភាពគណបក្ស នយោបាយនោះក៏ដោយ ។

**មាត្រា ៤២.-**

ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

**មាត្រា ៤៣.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយតាមការកំណត់របស់អុនតាក់ឆ្នាំ១៩៩៣ ត្រូវបញ្ជូនសំណុំឯកសារតាមការកំណត់ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ លើកលែងតែចំណុចទី ១១ មកតម្កល់ទុកនៅក្រសួងមហាផ្ទៃវិញ ក្នុងរយៈពេល ៩០ថ្ងៃយ៉ាងយូរ ។

បើហួស រយៈពេលដូចបានកំណត់ខាងលើនេះ ត្រូវចាត់ទុកថាគណបក្សនយោបាយនោះបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយ ។

# ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៤៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤៥.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រធានរដ្ឋស្តីទី

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី